**សុន្ទរកថា**

**ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃគ.ជ.អ.ប ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

**ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារ INTERCONTINENTAL**

- សូមគោរព ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ន
- ឯកឧត្តម លោកជំទាវ លោក លោកស្រីជាសមាជិកអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃគ.ជ.អ.ប
- ឯកឧត្តមប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវអគ្គនាយក អគ្គនាយិកានៃក្រសួង ស្ថាប័នពាក់ព័ន្ធ
- លោក លោកស្រីប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- លោក លោកស្រីតំណាងដៃគូរអភិវឌ្ឍន៍
- អង្គសិក្ខាសាលាទាំងមូលជាទីមេត្រី!

ជាបឋមក្នុងនាមក្រសួងមុខងារសាធារណៈ អនុគណៈកម្មាធិការបុគ្គលិកនៃគ.ជ.អ.ប និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការស្វាគមន៍ និងអរគុណចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនាថ្ងៃនេះ។

សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឱ្យបានជ្រួតជ្រាបនិងចូលរួមអនុវត្តខ្លឹមសារព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនេះ ឱ្យមានប្រសិទ្ធភាព ព្រមទាំងផ្តល់ជាគំនិតបន្ថែមក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាបន្ត

ទៀត សំដៅអនុវត្តខ្លឹមសារនៃព្រះរាជក្រឹត្យនេះឱ្យបានគ្រប់ជ្រុងជ្រោយ ព្រោះអនុលោមតាមព្រះរាជក្រឹត្យនេះ ក្រុមការងារនៃក្រសួងមុខងារសាធារណៈនិងក្រសួងមហាផ្ទៃ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃគ.ជ.អ.ប ត្រូវត្រៀមរៀបចំខ្លឹមសារព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំមួយចំនួនទៀតពាក់ព័ន្ធដូចជា ការរៀបចំឱ្យមានអង្គ ការកំណត់មុខតំណែងក្នុងអង្គ ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ ការរៀបចំនិយាម លក្ខខណ្ឌ និងដំណើរការនៃការជ្រើសរើស ការដាក់ឱ្យធ្វើកម្មសិក្សា ការតាំងស៊ប់ ការតែងតាំងនិងបញ្ចប់មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្ទេរនិងការផ្លាស់ប្តូរកន្លែងធ្វើការ ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សជាដើម។

ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងដោយអនុលោមតាម (១)ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥(២)កម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០១០-២០១៩ (៣)គោលនយោបាយស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (៤)ច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង(៥)ច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ខ្លឹមសារជារួមនៃព្រះរាជក្រឹត្យនេះ រៀបចំឡើងក្នុងគោលបំណងផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសមត្ថភាព ផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ដើម្បីសម្រេចនូវគោលបំណងខាងលើនេះ ព្រះរាជក្រឹត្យនេះបានកំណត់នូវគោលដៅជាសារវន្តបីសំខាន់គឺ (១)រៀបចំនិងគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (២)រៀបចំនិងគ្រប់គ្រងបុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (៣)កំណត់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែងនិងប្រើប្រាស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជាក់បន្ថែម៖ ចំពោះការឡើងថ្នាក់ និងឋានន្តរស័ក្តិក្រសួងមុខងារសាធារណៈ មិនអាចធ្វើដោយស្វ័យប្រវត្តិបានទេ គឺត្រូវមានសំណើពីក្រសួងស្ថាប័ននីមួយៗ ដែលគ្រប់គ្រងមន្ត្រីផ្ទាល់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!**

ក្នុងនាមក្រសួងមុខងារសាធារណៈ ខ្ញុំសូមស្នើសុំដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់ដែលបំពេញការងារពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកមេត្តាយកចិត្តទុកដាក់សិក្សាស្វែងយល់និងចូលរួមអនុវត្តខ្លឹមសារនៃព្រះរាជក្រឹត្យនេះឱ្យបានច្បាស់លាស់ ក្នុងនោះខ្ញុំសូមលើកយកចំណុចដែលត្រូវចាប់អារម្មណ៍មួយក្នុងចំណោមចំណុចពាក់ព័ន្ធជាច្រើននោះគឺវិសាលភាពនៃព្រះរាជក្រឹត្យនេះ។ ព្រះរាជក្រឹត្យនេះរៀបចំឡើង មានវិសាលភាពគ្របដណ្តប់ចំពោះបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជារួមមាន (១)បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានជ្រើសរើសនិងតែងតាំងដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (២)បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នដែលត្រូវបានផ្ទេរតាមដំណើរការនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (៣)មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នដែលត្រូវបានតែងតាំងឬចាត់តាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (៤)បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលរួមមាន មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលត្រូវបានជ្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ខ្លឹមសារនៃព្រះរាជក្រឹត្យនេះ មិនមានវិសាលភាពគ្រប់ដណ្តប់ចំពោះមន្ត្រីរាជការនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលឬមន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សដែលបំពេញការងារនៅថ្នាក់ក្រោមជាតិឡើយ។ ដើម្បីឱ្យកាន់តែយល់ច្បាស់ពីខ្លឹមសារទាំងស្រុងនៃព្រះរាជក្រឹត្យនេះ ខ្ញុំសង្ឃឹមថា ក្រុមការងាររៀបចំសិក្ខាសាលានិងសមាជិក សមាជិកាទាំងអស់នៃអង្គសិក្ខាសាលាទាំងមូលនឹងសិក្សាស្វែងយល់រួមគ្នានៅពេលបន្តិចទៀតនេះ។

ខ្ញុំសូមឆ្លៀតឱកាសដ៏មានតម្លៃនេះ បញ្ជាក់ជូនអង្គសិក្ខាសាលាជ្រាបថា មុនពេលខ្លឹមសារនៃព្រះរាជក្រឹត្យនេះត្រូវបានរៀបចំដាក់ឱ្យអនុវត្ត រាជរដ្ឋាភិបាល បានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនពាក់ព័ន្ធការគ្រប់គ្រងមន្ត្រី ក្នុងន័យផ្តល់សិទ្ធិអំណាចដល់ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ មានសិទ្ធិក្នុងការគ្រប់គ្រងមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួនផ្ទាល់ឱ្យឆ្លើយតបនឹងប្រសិទ្ធភាពការងារ ដូចជា ការអនុញ្ញាតច្បាប់ឈប់សម្រាកជូនមន្ត្រីរាជការ ការគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យា ការគ្រប់គ្រងវត្តមានការងាររបស់មន្ត្រី ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងជាដើម។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន**!

ក្នុងនាមក្រសួងមុខងារសាធារណៈ អនុគណៈកម្មាធិការបុគ្គលិកនៃគ.ជ.អ.ប និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំសង្ឃឹមថា (១)ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (២)កម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០១០-២០១៩ និង(៣)គោលនយោបាយស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពិតជាទទួលបានជោគជ័យជាក់ជាមិនខាន តាមរយៈការចូលរួមអនុវត្តខ្លឹមសារនៃព្រះរាជក្រឹត្យនេះនិងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន ព្រមទាំងលិខិតបទដ្ឋានគតិ-យុត្តដែលកំពុងតែត្រៀមរៀបចំជាបន្តបន្ទាប់ដើម្បីចូលរួមអនុវត្តខ្លឹមសារនៃព្រះរាជក្រឹត្យនេះ។

ជាមួយនឹងក្តីសង្ឃឹមនេះ ខ្ញុំសូមអំពាវនាវចំពោះសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូលសូមជួយផ្តល់ជាគំនិតមួយចំនួនដល់ក្រុមការងារដើម្បីជាទុន ឬ ជាធាតុចូលបន្ថែមទៀតក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រសម្រាប់ការអនុវត្តឱ្យឆ្លើយតបនឹងស្ថានភាពជាក់ស្តែងនៃការគ្រប់គ្រងធនធានមនុស្សឱ្យមានភាពបត់បែនតាមមូលដ្ឋាននីមួយៗនិងទៅថ្ងៃអនាគត ព្រោះខ្លឹមសារទាំងស្រុងនៃព្រះរាជក្រឹត្យនេះ មិនទាន់អាចយកទៅអនុវត្តលើកគ្រប់ករណីទាំងអស់ដែលកំពុងជួបប្រទះនៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅឡើយ។

ជាទីបញ្ចប់ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ និងអង្គសិក្ខាសាលាទាំងមូល សូមបានប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិចាប់ពីពេលនេះតទៅ៕

***សូមអរគុណ !***